មិត្តទាំងបួននេះដេញតាមមាន់ខ្ទាយចូលតាមព្រៃគុម្ពោត ដែលមានទួកៀសខ្លួនទៅ ។ ទំលពេជ្រសួរអ្នកស្រុកម្នាក់ថា

- វាទៅណាហើយ ?

- ខ្ញុំមិនដឹងថាគេទៅខាងណាទេ ប៉ុន្តែដែលខ្ញុំដឹងគឺគេទៅបាត់ទៅហើយៗហើយប្រហែលជាមិនជិតឡើយ !

មិត្តទាំងបួនបញ្ចូលដាវក្នុងស្រោមវិញ ដោយពោលថា :

- គង់តែយើងជួបនឹងវាទេ ថ្ងៃក្រោយ ! អានេះវាចូលដៃនឹងខ្មាំងទៀត រួចមិនប្រាប់ឯង ។

ពិតមែន មិត្តទាំងបួនបានប្តេជ្ញា ថានឹងសម្លាប់មាន់ខ្ទាយដោយចែបខាងលើនោះឯង ហើយសន្យាថាមិនសម្លាប់មាន់ខ្ទាយម្នាក់ឯងឡើយ ។

× ×
×

ផែនការសម្ងាត់

ក្បួនការពារណគរាជ្យ បានមកដល់ស្រុកមង្គលបុរី ។ គឺនៅទីនេះហើយដែលព្រះនាងខត្តិយាណីកែវមណីបម្រុងនឹងសម្រេចផែនការទីពីររបស់នាង គឺផែនការផ្តាច់ជីវិតព្រះកម្ពុជា ឥពុកមា រួមទាំងផ្កាមួយមេទ័ពកាយា និងសហជីវិនខ្លះដែលគេអាចរាប់អស់ទឹងម្រាមដៃ មានទំលពេជ្រ និលឯក បក្សីដាវើម ។

គឺចំនួនមនុស្សមួយក្តាប់ខាងលើនេះហើយ ដែលសង្កត់កន្ទ្រាប់មិនធាក់ ។

មួយថ្ងៃផុតទៅ ការតឹងតែងក្នុងស្រុកក៏រឹតតែកើតឡើង ។ គំនិតដាច់លើសសវាសារស្រុកទាំងអស់ ដើម្បីតំឡើងខ្លួនឲ្យខ្ពស់ផុតគេផុតឯង ធ្វើឲ្យមនុស្សដែលចិញ្ចឹមគំនិតនេះ គិតចេះតែខុស ប្រព្រឹត្តចេះតែឆ្គង ៗ ។

មើលហ៎ ។ ផែនការព្រះនាងមណីចេះតែអាក្រក់ទៅៗតតក្រៀម ។

ក្នុងរាត្រីនោះ កញ្ញាឯកបានប្រជុំអស់សហជីវិន ដើម្បីឲ្យគេទាំងនេះទទួលកិច្ចបញ្ជាជាចុងក្រោយបង្អស់ ។

ក្នុងរាត្រីដដែលនេះ មានក្មួយហារចោរនៅចល់ផែនដែលពីតាវេតិស្លាប់ជាស្លាប់ទៅហើយនោះ កំពុងទទួលទានបាយយ៉ាងស្ងប់ស្ងៀម

ស្រួលចូលជាមួយតាគីរីសុមេរុក្នុងផ្ទះតៀមតូចមួយ ។ មានន្ទអង្គុយនៅមាត់បង្អួចដៃកាន់ភ្លៅមាន់បរិភោគយ៉ាងឆ្ងាញ់ពិសា ។

នៅពីមុខផ្ទះតៀមនេះ គេហដ្ឋានមួយដ៏ស្កុកស្កត់លើកកម្ពស់ត្រដែតទៅក្នុងមេឃងងឹត ។ យូរ ៗ មានន្ទបង្អើបស្បៃបង្អួចចោលកន្ទុយភ្នែកទៅលើស្លាបព្រិលមាត់ទ្វារនៃគេហដ្ឋានដ៏ស្កុកស្កត់នោះ ដែលបិទជិតឃើញតែពន្លឺចង្កៀងព្រឹម ៗ មកខាងក្រៅ ។

មានន្ទសួរតាសុមេរុថា :

- ផ្ទះនោះជាផ្ទះអ្នកណា ?

តាសុមេរុសម្លឹងមើលតាមមានន្ទ មាត់ទំពាសាច់មាន់បណ្ដើរ តបបណ្ដើរ :

- ផ្ទះនោះ គឺជាផ្ទះព្រះកន្លាចន្ទ ។ ពីដើមគេមានប្រាក់ច្រើន គេតែងសង់ផ្ទះគ្រង់នេះ គ្រង់នោះ សម្រាប់មកលំហែលេង ។ រួចគ្មានអ្នកណាមួយហ៊ានចូលសម្រាក ឬ ចូលលេងក្នុងផ្ទះនោះបានឡើយ ។ មើលចុះ តាមិនដែលឃើញមាត់ទ្វារ និង មាត់បង្អួចផ្ទះនេះបើកម្ដងណាទេ គឺឃើញតែគេបិទផ្លូវទ្វារនោះឯង ។

មានន្ទសញ្ជឹងគិត ចងចិញ្ចើម ។ បុរសនឹកស្ដាយស្ត្រីអ្នកក្រដែលអត់ផ្ទះនៅ ក្មេង ៗ អត់សាលារៀន ។ល។ អ្នកក្រឈ្លាល ! រួចគ្រវាត់ឆ្អឹងមាន់ប្រួសទៅលើក្ដារនិយាយថា :

- ទេ ! ពេលនេះ មានមនុស្សចូលមកប្រជុំនៅទីនោះឯង ។ ខ្ញុំចង់ដឹង តើគេប្រជុំរឿងអី ?

តាសុមេរុនិយាយសំឡេងធ្ងន់ ៗ ថា :

- ហ៊ឹស ! គេធ្វើអី ! គេមានអីធ្វើ ក្រៅពីប្រជុំគ្នាដើម្បីបង្កកល្បិចឃុតអ៊ីមួយនោះ ត្បិតចៅស្រោបស្រាប់ហើយស្ត្រីកែវមណី គេប្រជុំនោះ ។

- មែន ! ខ្ញុំឃើញស្ត្រីនោះរំកិលខ្លួនចូលទៅក្នុងផ្ទះនោះឯង រួចកាមា រួចនិលពេជ្រ រួចនិលឯក ។

តាគីរីក្រោកឈរចាក់ទឹកតែពីកែវផឹកដង្ហើមធំ រួចនិយាយថា :

- ណ្ហើយចៅអើយ ! តាមតែគេទៅ គេធ្វើអីក៏ធ្វើទៅចុះ ។ តែតាបានជួបចៅពេលនេះ តាចង់និយាយលេងជាមួយចៅឱ្យបានយូរ តែខ្លាចចៅរវល់គំនិតពេក ។

មានន្ទឈប់មើលទៅផ្ទះខាងមុខ បែរមកចាប់ពែងតែផឹកក្អឹក នៅធ្មឹងឥតមើលមុខតាគីរីឡើយ ! តាគីរីបម្រះខ្លួនទៅលើជើងម៉ាមួយវែង អុជខ្សៀបក្ដួយផ្សែងនិយាយថា :

- ប្រហែលចៅមិនចង់ស្ដាប់តាទេ ពីព្រោះចៅមិនដឹងចិត្តតាសោះ

មានន្ទរិះរកមើល តើតាគីរីជាទីគោរពនេះចង់និយាយអំពីអ្វី ? អ្នកនឹកយល់ថា ប្រហែលតាគីរីចង់និយាយពីខាងទេវកាឡកិណ្ណីហើយ ។ មនុស្សវ័យចាស់ក៏ឆ្លៀតនេះឡើងឥតស្រាកស្រៀមឡើយ ។ អ្នកខាំធ្មេញញ័រអស់បេះដូង ។ បើក្រៅពីតាគីរី មានន្ទមុខជាវាយដំមិនខាន ។ តែ . . . នេះនោះទឹងយ៉ាងណាក៏ត្រូវតែគោរពគាត់ជាចាស់ទុំដែរ ។

មានន្ទធ្វើជាសើចតិច ៗ :

- ហាស ៗ ! លោកតាចង់មានប្រសាសន៍ពីអីសុំឱ្យមានប្រសាសន៍មក !

ធ្លាប់ស្គាល់ខ្ញុំស្រាប់ !

- អើ ! តាដឹងហើយថាចៅមានចិត្តខ្លាំង ចៅមានចិត្តដាច់ ។ តាសរសើរចៅណាស់ ព្រោះថា កើតមកជាកូនប្រុសត្រូវតែមានចិត្តដូច្នោះឯង . . .

មាននួញញឹមស្ងួត តែចុកណែនអស់ដើមទ្រូង មុខឡើងក្រហម តែបុរសស្តាប់ឥតប្រកែកឡើយ ដូចតទៅ :

- តាចាស់ណាស់ហើយ បន្តិចទៀតតាស្លាប់ទៅបាត់ ។ ចៅក៏កាន់តែចាស់ទៅដែរ ។ លុះដល់ថ្ងៃមួយចៅដឹងវិញ ពេលនោះទើបចៅនឹកដល់តាថា តាបាននិយាយលេងផង មែនផង ជាមួយចៅ ។ ហ៊ឺ ! ចៅអើយ ! យប់នេះប្រហែលជាយប់តែមួយទេដែលតានិយាយរឿងមួយជម្រាបចៅ គឺរឿងអស្ចារ្យមិនដែលមាន ។

- រឿងអីលោកតា ខ្ញុំចង់ដឹងណាស់ មានប្រសាសន៍មកកុំព្រួយបារម្ភអី ខ្ញុំស្តាប់ទាំងអស់ បើជារឿងល្អខ្ញុំតាម រឿងអាក្រក់ខ្ញុំមិនតាម ។

- អឺ ៗ ! ប្រសើរណាស់ ! ប្រសើរណាស់ចៅ !

តាគិរីលូកការ៉ុងហោប៉ៅយកសំបុត្រមួយមកបង្ហាញមាននួ ។ មាននួស្ទុះក្រោកទៅជិតតាគិរីប្រាថ្នាយកសំបុត្រនោះមកមើលភ្លាម ។ តែតាគិរីរាំង :

- កុំអាល ៗ ជារឿងសំខាន់ណាស់ !

- សំខាន់យ៉ាងណា ខ្ញុំចង់ដឹង ?

- គង់តែចៅបានដឹងទេ

- សំបុត្រពីណាមក ?

- គង់តែចៅបានដឹងទេ

- និយាយពីអ្វី ?

- គង់តែចៅបានដឹងទេ ! តែមុននឹងយកសំបុត្រនេះ សូមចៅសច្ចាឱ្យតាសិន !

- សច្ចាយ៉ាងណា ?

- សច្ចាថា មើលសំបុត្រនេះចប់ចុងចប់ដើម មានអារុក្ខទេវតា ព្រះឥន្ទ្រ ព្រះព្រហ្មអារក្ស អ្នកតាបិសាច បង់បត់ជាសាក្សី ។

- ខ្ញុំសច្ចា ! សច្ចាយ៉ាងណាទៀត ?

- សច្ចាថា មើលសំបុត្រនេះរួចឱ្យពិចារណា !

- បាទ !

- អើ ! មើលចុះ ។

ថាតែប៉ុណ្ណោះ តាគិរីបោះសំបុត្រប្រុសលើគុ ។ មាននួក្រសោរយកភ្លាមមកបើកឃើញអក្សរ ។ បុរសស្គាល់ជាក់ជាអក្សរនាងទេវី ។ បុរសហៀបគ្រវាត់សំបុត្រចោល តែតាគិរីធ្វើមុខស្មើរបែបនឹង ។ បុរសត្រជាក់អស់ខ្លួនប្រាណ រួចប្រឹងមើលសេចក្តីដូចតទៅ :

ក្នុងព្រៃ ថ្ងៃ១៥ កើត ខែបុស្ស គ.ស ១៨៦៨

សំណេរចំពោះបងមាននួជាទីគោរព

ក្នុងពេលដែលបងកំពុងមើលសំបុត្ររបស់ប្អូននេះ ព្រលឹង

ប្អូនកំពុងស្ថិតនៅក្នុងពពកនាស្ថានទេវលោក ។

ក្នុងស្ថានថ្មីនេះ ប្អូនបានសុខសប្បាយក្រៃណាស់ និងរកអ្វីមកផ្ទឹមពុំបានឡើយ ។

ចោលកន្ទុយភ្នែកមកលើស្ថានមនុស្សវិញ ប្អូនសើចព្រោះឃើញបងកំពុងហែលឆ្លងវដ្តសង្សារដ៏លំបាកដូចប្អូនបានហែលឆ្លងរួចមកហើយ ។

ថ្ងៃមួយ ដល់បងដល់ត្រើយសុខដូចប្អូន បងនឹងឈរមើលអ្នកជាន់ក្រោយ ។ ប្រវេប្រវាហែលឆ្លងដូចយើងទៀតមិនខាន រួចបងមុខជាសើច ដូចខ្ញុំសើចនឹងបងក្នុងពេលនេះ ។

ឱ! ប្អូនថាបងកំពុងហែលឆ្លងសមុទ្រទុក្ខដូចប្អូនបានហែលឆ្លងនោះខុសទេ ព្រោះថាទុក្ខប្អូនខុសអំពីទុក្ខបងស្រឡះ ។

ទុក្ខប្អូន គឺទុក្ខស្នេហាលើរូបបង ។

ក្នុងមួយជាតិនេះ ប្អូនបានទទួលស្នេហាតបពីបងវិញ តែត្រឹមថ្ងៃបងបែកពីប្អូនទៅច្បាំងប៉ុណ្ណោះទេ ។ ចាប់ពីពេលដ៏អស្ចារ្យនោះមក គឺប្អូនមានតែទុក្ខរហូតដល់ដាច់ខ្យល់ស្លាប់ ។ ដោយប្អូនបានដល់ត្រើយសុខទៅហើយ ប្អូនខ្លាចអីនឹងរំលឹករឿងស្នេហាដែលប្អូនបានលេងជាមួយបង ។ គឺថា ប្អូនបានស្គាល់ទិវានឹកបំផុតរបស់ស្ត្រីកំព្រាព្រាត់ប្ដី ។ បងនឹកឃើញទេ បងទៅច្បាំងប្អូនចាំ ៗ ចាំជាតំ ៗ ។ ប្អូនបីកូនចាំមើលផ្លូវបង ។ ទឹកភ្នែកហូរ ៗ ជាថ្លុក ជាអូរ ជាស្ទឹង ជាទន្លេ ជាសមុទ្រ ។

សម្រេចបងមិនឃើញត្រឡប់មកសោះ ។

ថ្ងៃបងមកដល់ ។ ប្អូនស្មានថា ប្អូនផុតទុក្ខដែលធ្លាប់ត្របកប្អូនហើយ ។ តែឥតសូវគ្នោះទេ បងមិនយល់ប្អូន បងខឹងនឹងប្អូន ដោយគេចោទប្អូននោះផ្ដេសពេកហួសវិស័យប្អូន ។

ប្អូនមិនបន្ទោសបងថា មិនចេះពិចារណាឲ្យវែងឆ្ងាយនោះទេ គឺព្រោះឥឡូវនេះប្អូនដឹងច្បាស់ថា ធម្មតាមនុស្សតែងកាន់ប្រឡំជានិច្ច ។

ដល់ពេលក្រោយ ប្អូនពកូនតាមបង ដើម្បីទៅពន្យល់បង និយាយនឹងបងថា បើរឿងពិតដែលប្អូនស្រឡាញ់បងនោះ ពុំគាប់ចិត្តបងទេ ពេលនោះប្អូនប្ដេជ្ញាថាប្អូនសុំផ្ដាច់ជីវិត ។ តែរកបងមិនឃើញសោះ ។

ទុក្ខប្អូនក៏ចេះតែមានរាល់ថ្ងៃ រាល់ខែ រាល់ឆ្នាំទៀត ។

ថ្ងៃមួយ មនុស្សម្នាក់បានជួយប្អូន និង បទុមកូនយើងឲ្យរួចពីកណ្ដាប់ដៃកាហា ។ មនុស្សសប្បុរសនេះ បាននាំប្អូនទៅរកបងឯភូមិថ្មី ស្រុកត្នៀត ដោយបានជួយលាក់បំពួនប្អូនឥតឲ្យអ្នកណាដឹងឡើយ ។

ពេញមួយឆ្នាំគត់ ប្អូនលបមើលឃើញតែគេឯទៀត ឯរូបបងមិនដែលឃើញ ។ ប្អូនក៏ចាប់ឈឺ ៗ ឱ! ឈឺត្រាតែ... ដូចបងជ្រាប ។

នេះហើយគឺសមុទ្រដែលប្អូនហែល !

ចុះពលកិលសមុទ្រដែលបងកំពុងហែលវិញនោះយ៉ាងណា ?

សំឡូវបងហែលម្នាក់ឯង គ្មានគូ ! ចំណាប់មែន ! ជាពិសេស ជីវិតបងជាជីវិតតស៊ូ តស៊ូនឹងធម្មជាតិ តស៊ូនឹងខ្យល់ តស៊ូនឹងកិច្ចការ ។ ប្រសើរពេក ។ ជីវិតបងខុសពីជីវិតអ្នកឯទៀត ។ ទុក្ខរបស់បង គឺទុក្ខរបស់រាស្ត្រខ្មែរ ។ ក្តីវេទនារបស់បងគឺក្តីវេទនារបស់សង្គមខ្មែរ បងមានការធ្វើច្រើន ។ គឺកិច្ចការនេះហើយ ដែលបំភ្លេចបងមិនឲ្យនឹកនាដល់ប្អូនដែលស្រឡាញ់បង ហើយមិនឲ្យនឹកនាដល់ស្រីឯទៀត ។

ដូចនោះ បងព្រាងរឿងយើងហើយ ! ប្អូនសូមលាហើយណាបងសម្លាញ់ ។

ទេ ! បងភ័យក្រែងប្អូនចងគៀរនឹងបងឬ ? ទេកុំភ័យដល់ថ្ងៃដែលមានមច្ចុរាជអញ្ជើញបងឲ្យចាកផុតស្ថានកណ្តាល ថ្ងៃនោះប្អូននៅចាំទទួលបងមិនខាន ។

នៅចុងក្រោយបំផុត ប្អូនសូមឲ្យបងមានជ័យជម្នះក្នុងដំណើរការរបស់បងដើម្បីជាតិខ្មែរ ដើម្បីប្រទេសខ្មែរ និងដើម្បីប្រជាជនខ្មែរ ។

ដោយសេចក្តីរាប់អានយ៉ាងខ្ពង់ខ្ពស់!

ទេវី

អានសំបុត្រនេះចប់ ទឹកភ្នែកពីរដំណក់ស្រក់យ៉ាត់ ៗ ពីភ្នែកមានខ្នង ។ គាត់រឹតទៅស្ងៀម ។ មានខ្នងខាំធ្មេញប្រឹងបង្ក្រាបតណ្ហាដែលត្រឡប់មក



ទូងកាំបិតស្រាប់តែខ្ទាតចេញ ប្រុកកាំបិតធ្លាក់ទៅក្រោមជើង
ការ៉ូយហូតកាំបិតមួយទៀត ។

គ្របដណ្ដប់ខ្លួនវិញ ។ តណ្ហានេះដែលក្រាបស្រពោនយូរមកហើយស្រាប់តែងើបផុសស្ទុះឡើងប៉ីដូចទឹកដែលបាក់ទំនប់ ។ ទឹកនេះហូរខ្លាំងក្រៃណា ខ្លាំងធ្វើឲ្យវីរបុរសវិលក្បាលព្រួសរងើង។ ហេតុកូនកាំបិតស្នៀតភ្លែត មានន្ទប្រឹងអស់ទំហឹងលើកបុកចុងផ្ដើមដោយឥតនិយាយមួយម៉ាត់ឡើយ ។ កូនកាំបិតស្រាប់តែខ្ទាតផឹង របូតពីដៃធ្លាក់ទៅចំហៀងជាមួយកូនកាំបិតមួយទៀត ។

តាគីវ៉ាញញឹមស្ងួត មើលមុខមានន្ទដែលញ័រអស់ទាំងខ្លួន ។ តាគីវ៉ាក្រោកឡើងដើរមួយ ៗ ទៅរើសកូនកាំបិតរបស់គាត់ដែលគាត់បានចោលទៅ ត្រូវកូនកាំបិតរបស់មានន្ទ កាលមានន្ទលើកចាក់ខ្លួនឯង ។ រួចគាត់រើសកូនកាំបិតរបស់មានន្ទមកគោះការពុកមាត់ធ្វើព្រងើយ ។ មានន្ទស្ទុះទៅក្រោបលើភូកយំដូចកូនក្មេងព្រួសរងើក ។ គឺជាលើកដំបូងក្នុងមួយជីវិតនេះដែលយើងឃើញមានន្ទយំ ។

តាគីវ៉ាដកដង្ហើមធំ យកថ្នាំញាត់ខ្សៀជាថ្មី អុជរួចបឺតខ្សៀយ៉ាងស្ងប់ស្ងៀម ។

ឱ ! មានន្ទយំ ៗ មែន ! ហេតុតែចិត្តក្មេង ! ចេះតស៊ូ ចេះមានចិត្តទូលាយ ហ៊ានលះបង់បុណ្យសក្ដិទ្រព្យសម្បត្តិ សេចក្ដីស្នេហា ចេះគិតរៀបចំអង្គការបដិវត្តយ៉ាងល្អ ចេះមានប្រាជ្ញាវៃឆ្លាត ចេះគិតឃើញខុសត្រូវ តឲ្យអំពើពាលរត់ចូលមកចារឹកឲ្យធ្វើឃាតកម្មខ្លួនឯង ! ហ៊ឹះអស្ចារ្យមែន ! ចិត្តក្មេង ! នាមឈ្មោះល្អក្រអូប បើធ្លោយមួយពេលនេះឲ្យមោហ៍មកបាំងបាន អស់ហើយ ! ចប់ហើយ ! អស់កើតជាមនុស្សហើយ អស់ទៅជាខ្មែរស្នេហាជាតិហើយ !

តាគីវ៉ាត្រវីក្បាល មើលផ្សែងដែលហុយឆ្ពោះទៅលើ ។ យូរមកតាគីវ៉ានិយាយថា :

- ចៅ ! ក្រោកឡើង ធ្វើការយើងទៀត ។ យី ! ទៅរវល់អីអារឿងប្រពន្ធកូននោះ ។

ធ្វើការយើងទៀត ! ពាក្យនេះចោលស្នូរយ៉ាងខ្ទរឆ្លើយឆ្លងក្នុងក្រអៅចិត្តមានន្ទ ។ សតិសម្បជញ្ញៈរបស់បុរសក៏វិលត្រឡប់មកវិញបន្តិចម្ដង ៗ ។ ស្នូរមាត់តាគីវ៉ាទៅទៀតថា :

- តាដឹងហើយថា ចៅនៅក្នុងចិត្តខ្លាំង ។ តែចៅត្រូវជ្រាបថា រឿងស្នេហាដែលយើងបានជួបប្រទះ គឺគ្រាន់តែធ្វើឲ្យយើងមានអនុស្សាវរីយ៍មួយដោយឡែកក្នុងចិត្តយើងទេ ។ កុំយករឿងស្នេហាជារឿងសំខាន់ឲ្យសោះ ។ គ្មានបានការអីទេ ក៏ប៉ុន្តែយើងមិនត្រូវមើលងាយស្នេហាដែរ ។ ឯការដែលមានខ្លឹមសារពិត ៗ គឺការដែលយើងកំពុងធ្វើឯណេះទេ ! យើងកំពុងធ្វើការបដិវត្តន៍ ! មក ! ក្រោកឡើងបញ្ចប់ការងារយើងឲ្យស្រួល រួចដល់ថ្ងៃសេរីរបស់ជាតិយើង ចាំយើងដោះស្រាយរឿងស្នេហានេះឲ្យបានស្រួលទៀត ។

មានន្ទក្រោកអង្គុយដាក់ដៃទាំងពីរលើក្បាលជង្គង់ភ្នែកហើម មុខស្លុតនិយាយស្ទើរខ្សឹបថា :

- ចៅខុសហើយ ! ទទួលខ្លួនខុស ៗ មែន ។

ឆ្លៀតឱកាសនោះ តាគីវ៉ាបន្ថែមថា :

- អឺ ! បើចៅទៅរក្សត់ចៅ ម្ដេចក៏ទាន់រត់តាមចៅ ? ឃើញទេ?

រាងជាក់ស្ដែងណាស់ណ៎ា !

- បាទ ! មែន ! ខ្ញុំខុសស្រឡះ ។

មានទ្វាររំញ័រក្រិត ៗ ទឹកផល់កាយា ! បុរសស្ទុះត្រែតទៅបើកកំណាត់បាក់ដែលបាំងបង្អួចមើលទៅ។ គេហដ្ឋានដែលនៅពីមុខនោះទៀត។ មើលបណ្ដើរ បុរសនិយាយបណ្ដើរ :

- ហ៊ឺះ! អាណិតស្រីពេក ! អូនស្លាប់បាត់ទៅហើយ ទើបឯងភ្ញាក់ខ្លួនចង់ទៅរកផ្ទះនាងសំពះស្នាលាទោសស្រី !

ទឹកភ្នែកពីរដំណក់ស្រក់ជាថ្មីទៀត ។ បុរសហូតយកកូនកន្សែងពៀសសំពោរ។ តាតិរីបក្ដួយខ្សៀទ្រមឹងដែល ស្ដាប់បណ្ដើរផង ដកដង្ហើមធំផង។ មានខ្លួននិយាយទៀតថា :

- ឈប់គិត !

តាតិរីបខ្មែររៀងទើរចោល ដោយនិយាយថា :

- ចៅឃើញអ្នកណាខ្លះទៀត ចូលក្នុងផ្ទះនោះ ?

- ឃើញកាយា ឃើញយោធាហានជាច្រើន !

- ចុះចំពោះចៅ និង នាងកែវមណីយ៉ាងណាទៅបានជាឥឡូវបែបខ្វែងគ្នាម្ល៉េះ ?

- ហ៊ឺះ លោកតាអើយ ! ខ្ញុំទើបតែត្រូវចេញពីគុករបស់វាថ្មី ៗ នេះឯង ។

- ស្អីទៅគុកនោះ ?

- គុកណ៎ា លោកតា គឺគុកផ្ទុកគេដាក់ត្រីនោះណ៎ា ! គុកនោះចម្លែកណាស់ធ្វើអំពីដែក មានទ្វារមួយដែលគេចូលទៅបាន រួចចេញវិញ



—... ខ្ញុំ [illegible]...

មិនបាន ។ អ្នកនេសាទតែងយកលុចនេះទៅដាក់តាមច្រកផងអូរបង្កប់ក្នុងទឹក ។ លោកតាមិនដែលឃើញលុចទេ ?

- ហឹមិនដែលឃើញ !

- បាទ!គឺទៅបាត់ម្ដង ។ ខ្ញុំលបដើរតាមអូនមណី ។ ដល់ផ្ទះមួយនោះ ខ្ញុំចូលទៅតាមគេ ។ ស្រាប់តែចូលទៅឃើញមានទ្វារបិទជិត។ ដល់ទ្វារទីពីរ មានទឹកហូរដល់ទ្វារទីបីទឹកលិចរកដើរទៅទៀតមិនរួច ។ ខ្ញុំចេញមកវិញ ។ ហ៊ឺះ ។ ចេញឯណា ទ្វារបិទអស់ហើយ ។ ស្ទាបនាយ ស្ទាបអាយឃើញដែកប៉ុន ។ មេដៃ ។ បានជាស្ទាប ព្រោះងងឹតសូន្យឈឹង ។ ដល់ពេលនោះហើយទើបខ្ញុំដឹងថា ខ្ញុំជាប់លុចគេហើយ ។ ខ្ញុំមុជទៅបាតស្ទាបរកផ្លូវចេញ តែឃើញដែកត្បាញជាក្រឡាស្ដួចស្ដើងដែល ។ ខ្ញុំហែលទៅខាងមុខៗស្រួចរកច្រកចេញគ្មានទៀត ។ ខ្ញុំតោងដែកនៅតែទីនោះឯង រង់ចាំពេលស្លាប់ ។ ឱ ! លោកតាអើយ ! សំណាងខ្ញុំណាស់ ទឹកស្អឹងរាស្រកយ៉ាងខ្លាំងថា បើទឹកច្រើនបន្តិច ខ្ញុំដាច់ខ្យល់ស្លាប់ហើយ។ តែអូនមណីនឹកស្មានថា ខ្ញុំស្លាប់ប្រាកដ ព្រោះប្រមាណជាបីថ្ងៃគត់ខ្ញុំអត់បាយសឹកតែទឹក ។

- ចៅធ្វើម៉េចទៅបានចេញរួចពីលុចចង្រៃនោះ ?

- ឈប់ ! ឈប់ ! ចាំខ្ញុំនិយាយឲ្យអស់ ។ ខ្ញុំស្ទាបសព្វគ្រប់ខ្នែងមិនឃើញមានច្រកចេញសោះ ។ ខ្ញុំគិតកាច់ដែក តែកាច់មិនកើត ខ្ញុំគិតកាច់ដែកទីងជាខ្ញុំតែកាច់មិនកើតទៀត ខ្ញុំក៏លះបង់គំនិតតស៊ូ។ មិនអស់ចិត្តនឹងមកស្លាប់ខ្លួនទទេ ខ្ញុំមុជរាវរកផ្លូវចេញទៀត ។ តែម្ដងនេះ ខ្ញុំប៉ះខ្មោចមួយ ។

អៃយ៉ា ! ខ្មោចនេះតើខ្ញុំព្រឺខ្លួនខ្លាចៗ នឹកថា បន្តិចទៀតខ្ញុំទៅជាខ្មោចដែរ។

- ធ្វើយ៉ាងម៉េចទៅបានចៅចេញរួច ?

- ងាយណាស់ខ្ញុំចេញតាមខ្មោច !

- តាមខ្មោច ?

- បាទ ! ដល់ចុងក្រោយបំផុត ខ្ញុំគិតស្រែកឲ្យគេឮដើម្បីឲ្យគេសង្គ្រោះខ្ញុំទៅតែស្រែកក៏គ្មានអ្នកណាឮ ។ ខ្ញុំឥតនឹកឃើញថា ខ្ញុំចេញតាមខ្មោចទេ តែអូនមណីស្រីនឹកឃើញខ្មោច ពីព្រោះមិនមែនស្រួលទេដែលនាងដេកលើខ្មោចនោះ ។

អាស្រ័យហេតុនេះហើយ បានជាអូនមណីនឹកថា បើខ្មោចជាប់លុចត្រូវតែដោះលែងខ្មោចវិញ។ ចុះលែងខ្មោចរបៀបណា ? ដោយថ្លក់ទាញម្ដងៗ ? ទេ ! ទេ ! អូនមណីជាស្រីឆ្លាតណាស់ ។ ខ្មោចស្អុយ ! ស្រីមិនចាំបាច់ថ្លក់ទាញឲ្យប្រឡាក់ដៃទេ ។ ស្រីបើកលុចឲ្យខ្មោចអណ្ដែតទៅតាមខ្សែទឹកជាការស្រេច ។ ខ្ញុំ ៗ ឱបខ្មោចទៅតាមខ្សែទឹកទៅ ! ងាយទេលោកតា ! បាទងាយណាស់ ! ខ្ញុំធ្វើជាខ្មោចទៅ រួចខ្ញុំបានរួចខ្លួនផុតខ្មោច ។

- លោកតា ឥឡូវដល់ពេលយើងចេញទៅក្រៅហើយ ។

- ទៅណា ?

- ទៅ ៗ ! ភ្លាម ៗ កុំបង្អង់ ។

ផងទាំងពីរក៏សៀតកាំបិតស្នៀតរៀងខ្លួន ដើរចេញពីបន្ទប់ផ្ទះគៀមនោះទៅ !

លុះទៅដល់ផ្លូវតូចមួយដែលព្រឹកស្ងាត់ មានន្ទផែបខ្លួននឹងគល់ឈើមួយ គាត់ក៏ផែបនៅគល់ឈើម្ខាងទៀត ។

មានន្ទនិយាយតិចៗថា :

- យើងចាំវានៅទីនេះហើយ ! មិនយូរទេ វាមកដល់ឥឡូវ !
- អ្នកណា ?
- គឺអាផាវានោះណា៎ !
- ន ! អាដែលតែងនិយាយថា វាសងសឹកឱ្យបាននោះឬ ?
- បាទ ! សងសឹកអាកាយា
- អឺ ! តានឹកឃើញហើយ វាថាវាសងសឹកដោយកាត់ដៃ កាត់ជើងអាកាយាមែនទេ ?
- បាទ ! ដោយសម្លាប់ឪពុកខ្ញុំ !

តាក៏ព្រឺខ្លងខ្លាក ។ មានន្ទបន្តទៀតថា :

- លោកតាដៀងឮលំអិ ការជាតិជាការជាតិ ឯការគ្រួសារជាការគ្រួសារ ។ ឪពុកខ្ញុំជាឪពុក ។ ព្រះកម្ពុជជាព្រះកម្ពុជ ។ តែក្នុងពេលនេះយើងចាប់អាផាវាឱ្យបាន ព្រោះព្រះកម្ពុជត្រូវរស់មួយគ្រាសិន ។ កុំទាន់អាលឱ្យគាត់ស្លាប់ ថាបើគាត់ស្លាប់ក្នុងពេលនេះ មុខជាអំណាចបានទៅដៃអាកាយា និង អ្នកមុណីមិនខាន ។

សព្វថ្ងៃព្រះកម្ពុជមិនត្រូវយោរយោខ្វែងលើយើង បានជាអាកាយាចង់សម្លាប់ចោល ។

- ទៅដឹងរឿងទាំងនេះពីណាមក ?

- ខ្ញុំមាននរុកក្នុងវាំងណាស់ ។ នៅជាមួយអ្នកមុណី មានស្រីម្នាក់ឱ្យការខ្ញុំ ។ ផែនការគេមានបីយ៉ាង ឥឡូវគេកំពុងសម្រេចផែនការទីពីររបស់គេ ។
- អ្នកណា ?
- នាងមាលាកូនពូនគុត ។
- អូ ! តាស្គាល់ហើយ
- អ៊ុះលោកតា ! វាចេញមកហើយ ! ក្នុងគ្រានេះយើងកាន់ភក្តីវាសនាជាតិ និងប្រជានុរាស្ត្រយើង ។ លោកតាឃើញអាផាវាទេ ដែលដើរមករកយើង ។ បើយើងចាប់វាមិនបាន វានៅធ្វើឃាតកម្មហើយ គឺស្អែកព្រឹកព្រះកម្ពុជត្រូវវាសម្លាប់ រួចស្អែកអាកាយាឡើងកាន់អំណាច ។ លោកតាឃើញទេ នោះហើយវាសនារាស្ត្រខ្មែរដែលកំពុងដើរ ។ កាយវិការតែមួយរបស់យើងដែលមិនបានសម្រេច កម្ពុជាមុខជាធ្លាស់ទឹកមុខមិនខាន ។

ផាវាដើរមកដល់ មានន្ទផ្លុំខ្លួនទៅទីងដើមឈើ តាក៏ភ័យញ័រចុងដៃ មានន្ទស្ទុះភ្លែតទៅទះស្មាផាវា :

- ស្ដូ ! មិត្តនិយាយគ្នាតិចបីម៉ាត់សិន !

ផាវាឈប់ :

- លោកគ្រូ ! ន ! ទៅណាមកណាទាំងយប់នេះ ?
- ចង់និយាយជាមួយផាវាឯង នៅកន្លែងស្ងាត់ណាមួយ ។
- អត់ទោសលោកគ្រូ ! យប់នេះខ្ញុំចង់តែនិយាយជាមួយទេវតា

ចំពោះឯង ។

អានន្ទកៀកដៃដារាជាប់ ទាំងពីរដើរខ្វាង អានន្ទសើចសប្បាយផងនិយាយថា :

- ថៃហ៍ ! ម៉េចក៏ដារាឯងមិនសុខចិត្តដើរលេងបន្តិច ជាមួយមិត្តភក្តិនោះ ?

ដារាធ្វើសញ្ញាថា ទទួលភារៈនេះ ហើយជនទាំងពីរក៏ដើរតម្រង់ទៅបន្ទប់ផ្ទះតៀមដែលអានន្ទជួល ។

អង្គុយជុំវិញតុ ពីមុខពែងតែ អានន្ទនិយាយថា :

- ទឹកតែនេះនៅក្តៅ ។ ឯចិត្តខ្ញុំក៏ក្តៅដូចទឹកតែ ព្រោះពេលនេះខ្ញុំបានឃើញមិត្តម្នាក់ គឺដារានេះឯង ។ ក្នុងជីវិតកំសត់របស់ខ្ញុំ ក្នុងពេលដែលខ្ញុំអស់សង្ឃឹមកាលណាខ្ញុំឃើញថា លើលោកនេះខ្ញុំមានតែម្នាក់ឯងមួយ គឺដារាឯងហើយដែលខ្ញុំនឹកដល់ ។ ខ្ញុំដែលមិនចេះនឹក ទោះឪពុកក្តី ប្រពន្ធកូនក្តី ខ្ញុំហាក់ដូចមានចិត្តចំពោះតែមួយ គឺនឹកដារាឯង ។ ដារាឯងជឿទេ ?

ដារាងក់ក្បាល :

- ជឿណាស់ លោកគ្រូ! បាទខ្ញុំជឿ ព្រោះតែលោកគ្រូហើយដែលថ្ងៃនោះបានចង្អុលប្រាប់ផ្លូវខ្មោចម្តាយខ្ញុំ ។ តាំងពីថ្ងៃនោះមក វង់មុខលោកគ្រូស្ថិតនៅជានិច្ចក្នុងវិញ្ញាណខ្ញុំ ។ ឥឡូវនេះ គឺយប់នេះមិនគួរណាឡើយខ្ញុំមកជួបមុខលោកគ្រូទេ ។ យប់នេះជាយប់ទីបំផុតនៃជីវិតខ្ញុំព្រោះវេលាដែលកល្បយុគមួយយ៉ាងអស្ចារ្យ ជិតដើរមកដល់ហើយ

ប្រហែលជាមានទេវតានាំផ្លូវលោកគ្រូដែលជាបុរសតែមួយ ដែលខ្ញុំស្រឡាញ់មកឲ្យជួបនឹងខ្ញុំ មើលទៅ ! លោកគ្រូ ! ខ្ញុំចង់សងសឹកមនុស្សដែលសម្លាប់ម្តាយខ្ញុំណាស់ ។

- អឺ ! មែន អាតាមាក់ស្រឡាញ់ម្តាយដារាឯងមិនបានដូចចិត្តវា ។ ក៏សម្លាប់ទៅ ។ អគុណណាស់ដារាឯង មិនបានទាន់ដង្ហើមគាត់ ។ មានតែខ្ញុំទេដែលបានទទួលពាក្យបណ្តាំរបស់គាត់យកដារាឯង ។ ឥឡូវគាត់សម្រាកក្នុងសន្តិភាពហើយ ។

ដារាខ្ទប់មុខយំ ៗ មួយស្របក់ ទើបនិយាយថា :

- លោកគ្រូ ! នាំឲ្យខ្ញុំនឹករឿងមួយដែលខ្ញុំខំភ្លេចជានិច្ច ។ ស្អែកនេះ ម្តាយខ្ញុំ បានខ្ញុំសងសឹកជួសហើយ !

- ដារាឯងសម្លាប់កាយា ?

- ទេ ! ហាស ៗ ទេ សម្លាប់ឪកាយា ដើម្បីឲ្យកាយាវេទនាតែលតោលម្នាក់ឯង ដូចខ្ញុំដែលតែលតោលមកហើយនេះ ។

- អ្នកណាឲ្យសម្លាប់ ?

- ព្រះនាងមណី ។ គឺជាការសម្លាប់មួយដែលមានតែអាទិទេពទើបដឹងមនុស្សក្បាលខ្មៅដូចយើងមិនដឹងការសម្លាប់នោះទេ ។ បាទ ! លោកគ្រូស្អែកខ្ញុំសម្លាប់ព្រះកម្មត ស្អែកសត្រូវលេខមួយរបស់លោកគ្រូដែលមិនហួសពីឪពុកលោកគ្រូ ត្រូវខ្ញុំសម្លាប់ជួសលោកគ្រូ ហើយដើម្បីសងសឹកជូនលោកគ្រូទៀត ។

- ផ្សឹតតែដារាឯង បាននិយាយការសម្លាប់នេះប្រាប់ខ្ញុំហើយ ឥឡូវ



ខ្ញុំត្រូវការឲ្យព្រះកម្ពុតរស់សិន ! ខ្ញុំសុំជីវិតព្រះកម្ពុត !

សូមប្រាប់ខ្ញុំមើល តើផារ៉ាឯងបម្រុងធ្វើយ៉ាងណា ដើម្បីសម្លាប់នេះ ?

ផារ៉ាគិតសញ្ជឹងបន្តិច :

- ខ្ញុំមិនឃើញថា មានប្រយោជន៍អ្វីទេ បើខ្ញុំលាក់បៀបសម្លាប់នោះមិនឲ្យលោកគ្រូដឹង ។ ស្អែកម៉ោងដប់ នៅចំពោះមុខព្រះសង្ឃសូត្រជយន្តោត្រង់កន្លែងផ្សារកណ្ដាលវាល ។ ព្រះកម្ពុតមកស្តាប់ព្រះសង្ឃជយន្តោដែរ អង្គុយបែរមុខទៅខាងកើត ។ ខ្ញុំពន្លួរសំពត់ស ស្លៀកសពាក់ស ធ្វើជាអាចារ្យចុះមកពីលើមេឃស្រោចទឹកឲ្យពរជ័យដល់ព្រះកម្ពុត ។ ក្នុងពេលស្រោចទឹកនេះខ្ញុំ . . . ហូត កាំបិតចាក់សម្លាប់ព្រះកម្ពុត ។

- ហេតុម៉េចក៏ចាំមខ្ទូរផង ?

- បើមិនខមខ្ទូរ គេស្គាល់ខ្ញុំហើយ !

- ងាយមែន ! តែផារ៉ា ខ្ញុំស្នើសុំខមួយពីផារ៉ាឯង ។

ផារ៉ារីករាយស្ពារដៃនិយាយថា :

- គឺជាកិត្តិយសមួយដ៏ខ្ពង់ខ្ពស់របស់ខ្ញុំ ដែលមុននឹងស្លាប់បានបម្រើមិត្តម្នាក់ដូចលោកគ្រូនេះ ។ មានប្រសាសន៍មកចុះលោកគ្រូ ! ខ្ញុំផ្តល់បាន បើខ្ញុំអាចផ្តល់បាន !

- ខ្ញុំត្រូវការឲ្យព្រះកម្ពុតរស់សិន ! ខ្ញុំសុំជីវិតព្រះកម្ពុត !

ផារ៉ាឡើងស្លាំងស្មារតីថា :

- លោកគ្រូត្រូវការឲ្យព្រះកម្ពុតរស់សិន ?

— ពិព្រោះ បើព្រះកម្ពុតស្លាប់ក្នុងពេលនេះ ខ្មែរច្រើនណាស់ដែលត្រូវស្លាប់ រួចកាយជាខ្មាំងឯងរស់ !

ផារ៉ាបើកភ្នែកធំ ៗ :

- ម៉េចក៏ដូច្នោះ ?

- ព្រោះអំណាចទាំងប៉ុន្មានមុខជាធ្លាក់ទៅក្នុងដៃកញ្ញាដែលជាអ្នកសម្លាប់ម្ដាយរបស់ផារ៉ាឯង !

ផារ៉ាខឹងមុខជ្រប់ ខាំធ្មេញ រួចងើបមើលមុខមានន្ទចងចិញ្ចើមហើយ បើមានន្ទមានត្រចៀកចិត្ត មានន្ទអាចឮពាក្យដូចខាងក្រោមនេះមិនខាន :

- លោកត្រូវសុំជីវិតព្រះកម្ពុត ? លោកត្រូវសុំអញ្ចឹង ? តែការសងសឹក . . . សេចក្តីស្នេហា . . . ព្រះនាងខត្តិយាណីដ៏ល្អស្អាតក្នុងលោក ស្ត្រីឆ្មើងរង់ចាំខ្ញុំយប់ស្អែកលើពូកស្អាតសាច់សស្គុស មុខស្រស់ចំណាប់ ដើម្បីផារ៉ាម្នាក់ឯងខ្ញុំ ។ គប្បីលោកត្រូវសុំកុំឱ្យខ្ញុំស្គាល់កាយរាគនឹងនោមស្រស់នេះ ?

ចម្បាំងមួយយ៉ាងធំកំពុងតែយុទ្ធគ្នាក្នុងទ្រូងផារ៉ា រួចនៅចុងបំផុតផារ៉ាពោលតិច ៗ ថា :

- ស្អែកព្រះកម្ពុតរស់ ៗ

មានន្ទសប្បាយចិត្តយ៉ាងក្រៃលែងនឹងពាក្យនេះ ។

× ×
×

ជោគជ័យ

ព្រះសុរិយារះចំកណ្ដាលរង្វង់ពណ្ណរង្សីទាំងប្រាំពីរថ្នាក់ ដែលមើលឃើញច្បាស់ក្រៃលែងជាទីអស្ចារ្យក្រៃពេក ។

ពពកបន្ទាយដើងឆ្ងាយវែងទៅដល់ជើងមេឃ ។ តាមចាស់ទុំ គឺពេទស្រុកសង្គ្រាម ។ ប្រជាជនដែលជាម្ចាស់ស្រុកងើបក្បាលទៅមើលគ្រប់ ៗ គ្នា ដើម្បីពិនិត្យហេតុដ៏ចម្លែកនេះ ។ ពាក្យថា “ ស្រុកមានកើតការប្រែ អ្នកធំស្លាប់ ” ផ្សាយចេញពីមាត់មួយទៅមាត់មួយ បង្កើតក្ដីខ្វាចក្នុងចិត្តគ្រប់ ៗគ្នា ។

មែន ថ្ងៃនោះគឺជាថ្ងៃដែលព្រះនាងខត្តិយាណីសម្រេចនូវផែនការដើម្បីខ្លួនឯង និងដើម្បីកាយា ។ ផែនការនេះជះចំហាយក្ដៅដល់ទៅទេវតាដែលយើងមើលមិនឃើញថែមទៀត ។

តើព្រះកម្ពុតស្លាប់ឬទេ ? តើព្រឹត្តិការណ៍ស្រុកខេត្តប្រែប្រួលទៅយ៉ាងណា ? យើងរំជួលចិត្តក្រៃពេក !

មួយគ្រានេះ បើព្រះនាងសម្រេចបំណងទាំងបីយ៉ាងគឺ ១_សម្លាប់មានន្ទបាន ២_សម្លាប់ព្រះកម្ពុត ៣_លួចមាសប្រាក់បាន នោះលទ្ធិ

ផ្ដាច់ការ ដូចជារោគត្បាតយ៉ាងឃោរឃៅលើប្រជានុរាស្ត្រខ្មែររាប់ម៉ឺននាក់ជាដាច់ខាត ។

តែអ្នកអានទាំងឡាយប្រាកដហើយថា ផែនការទីមួយរបស់មណីស្រីវិសេសរលំគ្រលង់ទៅចុងជើងរាស្ត្រយើងទៅហើយ គឺថាមានខ្លួនត ត្រូវស្លាប់ដូចស្រីខត្តិយាណីចង់នោះទេ ។

សួរថា : បើផែនការទីពីរ និងទីបីបានសម្រេច តើបំណងស្រីស្រស់ដែលចង់ជិះករាស្ត្រខ្មែរសម័យនោះបានសម្រេចទេ ?

យើងអាចឆ្លើយថា : ក្នុងពីរភាគបីបំណងស្រីចំណាប់អាចសម្រេចបាន ពីព្រោះថា បើព្រះកម្ពុតស្លាប់ដំណាក់បានទៅនាង រួចស្រីបានមាសប្រាក់ដើម្បីទិញអាវុធបន្តសង្គ្រាមជិះជាន់នោះទៅទៀតបាន ហើយបានយ៉ាងសាហាវមិនខាន ។

ហេតុនេះ គួរភ័យណាស់ពេក ព្រោះមហន្តរាយនៅមានចម្លងយ៉ាងធ្ងន់ធ្ងរលើសាសាជាតិយើង ។

តែប្រហែលផែនការទីពីររបស់ស្រីកំណាចមិនបានសម្រេចទេ ពីព្រោះយើកកានសឹងថ្មី ។ នេះទៀតថា ផាវាសុខចិត្តមិនសម្លាប់ព្រះកម្ពុតតាមសេចក្ដីស្នើរបស់មាននូក្នុងផ្ទះកៀប ។

អូស ! បានធូរស្រេងបន្តិច ! តែទេ ការពិតព្រឹត្តិការណ៍មិនទាន់បានធូរដូចយើងស្មាននោះទេ ។ តោងយើងនឹកសុភាសិតបុរាណដែលពោលថា: « *ធ្វើស្រែនឹងទឹក ធ្វើសឹកនឹងបាយ* » ។ ហេតុនេះ ទោះផែនការទីមួយ និងពីរមិនបានសម្រេចក៏ដោយ ក៏ព្រះនាងអាចបន្តសង្គ្រាម

យ៉ាងម៉ឺងម៉ាត់មិនខាន ដោយព្រះនាងបានលួចយកគ្រឿងទ្រព្យសម្បត្តិព្រះកម្ពុតទៅហើយ ។

មួយវិញទៀត កាលមុនគិតគូរគ្រោងការធ្វើក្បួនហៅ « *ការពារ ឯករាជ្យ* » នោះព្រះនាងបានបញ្ជូនបេសកជនសម្ងាត់ម្នាក់ ឲ្យទៅសុំកម្លាំងទ័ពពីឥស្សរជនសុរិន្ទ្រ និងសុំកម្លាំងទ័ពថ្មីពីព្រះចៅក្រុងអាយុធ្យា នៃប្រទេសសៀម ។

ដូចនេះខាងព្រះនាងឃើញថានៅមានកម្លាំងខ្លាំងដូចដើមរីសារនៅឡើយ ។

ន ! កាលបើស្រីមានជ័យជម្នះហើយ .... មនុស្សក្រៀមក្រំមិនខាន ព្រោះខាងមានតួអ្នកតស៊ូដើម្បីយើងទាំងអស់គ្នា ទោះមុខជាបរាជ័យហើយ ។

តែឥឡូវនេះ វែកញែកមើលកម្លាំងខាងមានទូទៅ តើខ្លាំងប៉ុន្មាន ? អាចស៊ូសងបានឬទេ ?

អូ ! គួរឲ្យអាសូរណាស់ ម៉ាតនូរដើរមកស្រុកមន្តួលបុរីតែពីរនាក់ គាំសុមេរុ ។ រួចណាមួយថ្ងៃនោះ ព្រះអាទិត្យចាំងចំក្រឡ់ក្ដៅពីរដងទៀត។

តែប្រវត្តិសាស្ត្រឆ្លើយថា : ខ្មែរឈ្នះ ! ឈ្នះព្រោះកម្លាំងខាងមានទូទឹងផ្នែកលើកម្លាំងរាស្ត្រ ហើយកម្លាំងប្រជារាស្ត្រតែងឈ្នះជានិច្ច។

ព្រឹកនោះ មនុស្សមកកុះករ ហែតួបីពីរ ពាំវាញនាកដែលគេតុបតែងលំអដោយស្លឹកឈើ និង ផ្កាគឺសម្រាប់ព្រះសង្ឃសូត្រជយន្តោ ។ គេឮស្នូរគេសម្រែកហៅ « ជយោ ! ព្រះកម្ពុត ជយោ ! ព្រះកម្ពុត » ។ រួចគេបានសប្បាយ នឹងមើលក្បួនសេះដំរីដែលដើរជាជួរប្រដាប់ដោយគ្រឿង

ថ្ងៃអស្ចារ្យ ដែលពណ៌លឿង ខៀវ ក្រហម ស លេចឃើញផងគេ ។

ព្រះនាងខត្តិយាណី និងនាងមាលាលបមើលក្បួនតាមចន្លោះបង្អួច ដែលនៅក្នុងផ្ទះស្នាក់តូចមួយជិតនោះ ។

ទឹកមុខព្រះនាងខត្តិយាណីមាំកោច ។ ផិតចាំមើលអាចារ្យផារា សម្លាប់ព្រះកម្ពុតនឹងភ្នែកស្រី ។

គ្មាននរណាមួយនឹកសង្ស័យដល់អាចារ្យនោះឡើយ ។ ឯចំណែក ព្រះកម្ពុតបានបង្គាប់មិនឲ្យគេយាមព្រះអង្គឡើយ ដើម្បីបង្ហាញឲ្យគេ ឃើញថា រាស្ត្រស្រឡាញ់មែន ។

ស្លៀកស្បៃលេចរលោងពណ៌មាសភ្លឺផ្លេក ៗ ជើងទទេ ដៃកាន់ ថាសដែលមានទៀនធូប ក្បាលទទេ ព្រះកម្ពុតដើរមួយ ៗ ចូលមកថ្វាយ បង្គំព្រះសង្ឃដែលគង់ចាំនៅត្រៀបត្រា ។

អ្នកស្រុកផងទាំងពួង មិនថាចាស់ឬក្មេង ស្រីឬប្រុស ងាកមើល មកលោកគ្រប់ ៗ គ្នា ។

កិច្ចសូត្រធម៌ថ្វាយបង្គំព្រះ ក៏ចាប់ផ្ដើមឡើងយ៉ាងពីរោះ ។ ព្រះ កម្ពុតបត់ជើងរម្យទមសំពះព្រះសង្ឃ ។ រួចយើងរាល់គ្នាស្ដាប់លោកសូត្រ ធម៌ប្រស់ទឹក ។ ធម៌ជយន្តោមកដល់ ។ ព្រះសង្ឃសូត្រចប់ ។ អាចារ្យ មួយរូបស្លៀកស ពាក់ស ទទូស ចេញមកពីមាត់ទ្វារមួយដើម្បីមកប្រស់ ទឹកជូនព្រះកម្ពុត ។

ព្រះនាងខត្តិយាណីរំភើបក្នុងចិត្ត កាលបើឃើញអាចារ្យនេះចេញ មក ។ ព្រះនាងគិតថា :

. . នុ៎ះ ! ឃាតករចេញមកហើយ ។

អាចារ្យប្រស់ទឹក ឲ្យពរដល់ព្រះកម្ពុតដែលលុតជង្គង់នេះឡើង សំពះទទួលពរជ័យ ។ ព្រះនាងដែលលបមើលរឿងនេះញ័រអស់ជើងដៃ ស្ទើរផុប ។ ពេលដ៏សំខាន់មកដល់ . . . ។ គឺពេលដែលព្រះកម្ពុត លុតជង្គង់នេះហើយដែលផារាត្រូវចាក់សម្លាប់វិញ ។

ព្រះកម្ពុតបត់ជើងចុះទៅវិញ ។ ព្រះនាងខត្តិយាណីផនខ្លួនបន្តិច ដើម្បីប្រឹងមើលឲ្យបានច្បាស់ ។ រួចគឺក្នុងពេលនោះហើយដែលអត្ថិឆ្ងល់ កេះក្នុងទ្រូងនាង ។

ព្រះកម្ពុតបត់ជើងទៅវិញ . . . រួចផារាវាមិនសម្លាប់ . . . !

ព្រះនាងខាំធ្មេញ និយាយក្នុងចិត្តថា :

- រឿងអី ? ហេតុម៉េចក៏ដូច្នោះ ?

សូរស្រែក « យកិញ » ក៏លាន់ឮឡើងយ៉ាងហើត ៗ ។ ព្រះនាង ខត្តិយាណីលុតជង្គង់ចុះដោយលបមើលទៀតលែងកើត ។

តើព្រះនាងនឹកយ៉ាងណាក្នុងពេលដ៏អស្ចារ្យនេះ ? តែភ្នែកស្រី នោះចាក់ទៅលើរូប ផារាដែលមកដល់ព្រឹបពីមុខនាង ។

ព្រះនាងស្ទុះទៅរកអាចារ្យឈប់ពីមុខបុរស ។ មួយស្របក់ព្រះ នាងសួរថា :

- ម៉េចក៏ឯងមិនសម្លាប់ ? យ៉ាងណា ? រឿងអ្វី ? ហ៊ឺះ ! ហ៊ឺះ ! . . . ចាំមើល !

តែរូបអាចារ្យដែលស្លៀកស ពាក់សនៅស្ងៀមតតើយឡើយ ។

ក្នុងពេលដដែលនោះ ស្ត្រីហូតកាំបិតស្នៀតខ្នាតតូចពីចង្កេះខាង ដែលនាងស្នៀតមិនដែលឃ្លាតឡើយ ។

អាចារ្យកន្ត្រាក់ខ្លួនបន្តិច ។ រួចសើចឮហឹស !

ព្រះនាងឮសំណើច ខូចចិត្តភ្លែតភ្លាម ។ ទើបព្រះនាងឮសំដីថា :

- ស្ងួនអូនមណី ! បងមិនចាំបាច់ឃើញមុខអូនទេ បានស្គាល់អូននោះ ។ បងគ្រាន់តែឮសូរសំដីអូន ក៏ស្គាល់អូនស្រេចទៅហើយ ពីព្រោះសូរសំដីរបស់អូនជាសូរសំដីដែលគេមិនអាចភ្លេចបានទេ ទោះនៅក្នុងផុតក៏មិនភ្លេចដែរ . . . ។ អូនចង់ដឹងថាបងជាអ្នកណា ? . . . មើលចុះ . . . ។

ព្រះនាងថយពីស្រោតខ្សែកទៅក្រោយ ។ មុខស្រាំឡើងស្លាំងដូចមនុស្សស្លាប់ រួចក្នុងពេលអាចារ្យកំពុងនិយាយ ព្រះនាងនឹកថា :

- គឺសំឡេងបងមាននួរហើយ ! ព្រោកឆហើយ ! រួចការស្លាប់នោះវាទៅជាយ៉ាងណាវិញ ? គឺសំឡេងនេះហើយដែលអញស្អប់ . . . គឺសំឡេងនេះហើយដែលអញស្រឡាញ់ . . . ។

ស្រីទៅស្ងៀមស្ងឹង ទន្ទេញតែក្នុងពោះថា :

- គាត់ស្លាប់បាត់ទៅហើយ ! អញប្រាកដជាគាត់ស្លាប់ រួចឥឡូវគាត់និយាយនឹងអញ ! រួចគាត់មកនៅនឹងមុខអញទៀត !

ពេលនោះ មានផ្កាបើកកន្សែងដែលខ្ទប់មុខឡើង ។ ព្រះនាងទត្តិយាណីញ័ររន្ធត់សន្លប់ ។ វិញ្ញាណព្រះនាងហិចហើរទៅណាអស់រលីង ។ ចិត្តចង់សម្លាប់មាននួ សេចក្ដីស្រេកឃ្លានចង់ស៊ីសាច់ សេចក្ដី



. . . អូនចង់ដឹងថាបងជាអ្នកណា ? មើលចុះ . . .

ខ្លាចស្លាប់នឹងដៃមាគន្ធវិញក៏ហួរមកក្នុងចិត្តស្រីបន្ទា ភ្ញាក់តស្រាកស្រាន្ត ។ ស្ទុះភ្នែកយារកាំបិតហៀបចាក់ មាគន្ធសើចឡេចភ្នែកនៅស្ងៀមស្ងឹង ហាក់ទទួលចុងកាំបិតនេះដោយរីករាយ ។

ព្រះនាងដែលឆេះពេញខ្លួនមកចាញ់ ។ ។ ទឹកមុខ ទឹកចិត្តដ៏ត្រជាក់នេះជាថ្មីម្តងទៀត ។

កាំបិតធ្លាក់ពីដៃស្រីប្រុសទៅលើក្តារ ។ មាគន្ធទៅជិតព្រះនាងមុខស្លូតពោលថា :

អូន ! អនុញ្ញាតឲ្យបងប្រាប់អូនម្តងទៀតចុះថា : អូនមានរូបល្អ អូននៅក្មេង ! ត្រឡប់ទៅសុរិន្ទវិញទៅ ! ធ្វើតែជាស្ត្រីធម្មតា ដូចស្រីឯទៀតប៉ុណ្ណោះបានហើយ ! អូនមុខជាបានសុខមិនខាន . . . ។ តោងអូនស្រឡាញ់សេចក្តីស្នេហា ។ សេចក្តីស្នេហាគឺជាជីវិតរបស់ស្ត្រីទាំងអស់ និងជាជីវិតរបស់បុរសទាំងអស់ ។ ទោះព្រះរាជក្តី អធិរាជក្តី ព្រះសង្ឃក្តី យាយជីក្តី ខាម៉ុនក្តី អ្នកជំនួញក្តី អ្នកស្រែក្តី គេតែងតែស្រឡាញ់ដរាប ។ ទៅ ! អូនទៅចុះ ! រួចសូមទុកឲ្យពួកយើងទាមទារដណ្តើមយកសេរីជីវិត គឺឯករាជជាតិ និងសេរីប្រជារាស្ត្រដែលមនុស្សត្រូវតែបាន មិនថាសៀម ចិន-ភូមា ឬ ខ្មែរទេ ។ អូនចង់សម្លាប់បង ! ប៉ុន្តែអូនយំ ។ ហេតុនេះហើយ បានជាបងសូមប្រាប់អូនដោយមេត្រីភាពដូចបានរៀបរាប់មកស្រាប់ ។ តែបើអូនមិនស្តាប់បងទេ . . . អូនបង្ខំឲ្យបងប្រព្រឹត្តឃាតកម្មឧក្រិដ្ឋមិនខាន ។ បងមិនចង់សម្លាប់មនុស្សទេ តែបើមនុស្សនោះចេះតែចង់សម្លាប់អ្នកឯងហួសហេតុពេក បងប្រែជា

ចង់សម្លាប់មនុស្សបែបនោះណាស់ទៅវិញ ។

ព្រះនាងខត្តិយាណីពេបមាត់បញ្ចេញមាក់ការៈកាច ។ នាងហាក់ដូចគ្មានត្រិះរិះនឹងសំដីចុងបំផុតរបស់មាគន្ធឡើយ ។ តើអ្នកណាអាចដឹងថាធីតាមានគ្រោងការអ្វីទៀត ។ ស្រីនិយាយតបថា :

. យើងជាខ្មាំងនឹងគ្នាដរាប ។

មាគន្ធចងចិញ្ចើមមុខឡើងក្រហមដូចគេវាយភ្លើង ។

- បើដូច្នោះគ្មានអ្វីផ្សះផ្សារយើងបានទេ ! មានតែអាវុធ ។

មាគន្ធហូតដាវផ្ទាប់តល់កព្រះនាងឥតបង្អង់ឡើយ ។ ព្រះនាងពេបមាត់ ។ ស្រីលាតត្រដាងដៃស្តាំទៅមាត់ទ្វារមួយជិតនោះ ដើម្បីឲ្យមាគន្ធមើលតាម ។

គាប់ជួនពេលនោះ ទ្វាររបើកភ្លូតឡើង ។

ទាហានចូលមក ។ លុះឃើញមាគន្ធដែលតម្រង់ចុងដាវតល់កព្រះនាង ទាហានដកដាវខ្លួនតិចតួចចូលមក តែធីតារាងៃ :

- កុំ ! កុំ ! មានការអី ?

- ព្រះបាទម្ចាស់មានសំបុត្រមួយមកពីព្រះចៅក្រុងអយុធ្យា ។

- អើ ! យកមកមើល ។

ទាហានចូលមក ធ្វើការគិប្បូរចហុចសំបុត្រ ។ ព្រះនាងលាមើលរួចហុចសំបុត្រនោះទៅឲ្យមាគន្ធមើលដូចតទៅ :

ពីព្រះចៅក្រុងអាយុធ្យា ដល់ព្រះនាងខត្តិយាណីកែវមណី

ខ្ញុំព្រះចៅក្រុងអយុធ្យាបានទទួលលិខិតរាយការណ៍ អំពី

មហាសេនា មានគ្នាហើយនិងអ្នកកំលាំងចក្រយើងដែលនៅស្លូត ស្មើននោះឡើយ ។

ជាអ្នកខ្ញុំមានព្រះច័យ ក្រែកអរនិងព្រះនាងណាស់ ដោយបានប្រឹងប្រែងតស៊ូតារគាររំលាភគ្រប់យ៉ាង ដើម្បីទ្រទ្រង់ការគ្រប់គ្រងរបស់ជាតិសៀមយើង ក្នុងអាណាខេត្តស៊ីសោភ័ណ។ សូមព្រះនាងបន្តការងារយើងទៅទៀត ។ ខ្ញុំបញ្ជូនមកជាមួយនេះនូវកងពលចំនួនប្រាំពាន់នាក់ក្រោយការ ដឹកនាំរបស់នាយសេរីវង្សក៏ដូចជាមួយនិងមាសចំនួនកន្លះហាប ដើម្បីបង្ក្រាបចលាចលសូមព្រះនាងប្រើប្រាស់តាមត្រូវការ ។

ខ្ញុំសូមឲ្យទេវតាជួយថែរក្សាព្រះនាង និង ស្នេហ៍គ្រងបានគង់វង្សយើងយូរអង្វែងសាងស្នាទោះទុកកុំខាន ។

ព្រះចៅ ក្រុងអយុធ្យា

ព្រះនាងញញឹម ងក់ក្បាលបញ្ជាឲ្យទាហាន :

- ទៅចុះ ។ ជាចំណែកខាងបង សុំផាត់ផាវចុះ ។

មានគ្នាញ៉ាស់បុត្រចោរឈរទៅលើក្ដារ ។ ព្រះនាងបន្តទៀតថា :

- បងចង់សម្លាប់ប្អូន ? ហ៊ឹះ ! បងមិនឃើញ ស្គាល់ប្អូនបើនឹងបងទេ ! ទៅ ។ កុំសម្លាប់ ពីព្រោះ . . .

គ្រាន់តែថាប៉ុណ្ណោះ ទ្វារមួយទៀតរបើកឡើង ។ ពេជ្ឈឃាដពីរនាក់ចាប់ដៃនាងទេវីម្នាក់ម្ខាង ។ ផ្ដាគចុងកាំបិតចឹងកនាង ។ ម៉ាត់នាងត្រូវគេចុកណែនាំងស្រែកពុំរួច ។



កាលបើពេលកាលគួ កាលណាព្រាត់ព្រាសតែងតែកើត
ស្វះស្វែងតែរកគ្នាកាលគូ ។

កាលបើឃើញមានន្ទ នាងក្រញ្ញាលអស់ទំហឹងចង់ស្ទុះរត់មករក មានន្ទ ។

រីឯមានន្ទ កាលបើឃើញនាងទេវីដែលអ្នកស្មានថា ស្លាប់បាត់ទៅហើយនោះប្រាសហៀបស្ទុះទៅចាប់ តែសំឡេងព្រះនាងមណីគំហកថា :

- នៅឲ្យស្ងៀម ! បើបងកម្រើកតែបន្តិចទេវីស្លាប់ហើយ !

មានន្ទមុខឡើងស្លាំង ញ័រដូចកូនសត្វ ។ តើធ្វើយ៉ាងណា ?

នាងមណីធ្វើព្រងើយ ផ្អែកខ្លួនទៅនឹងសសរ និយាយថា :

- ដូចបងនៅមួយចំហាយពីខ្ញុំ ។ ដាវខ្ញុំនៅជាប់នឹងកនាងទេវី។ បងឃើញទេ ? ខ្ញុំដើរមុខបងជានិច្ច ។ ឥឡូវសម្រេចយ៉ាងណា សម្រេចទៅ! ឬមួយលែងឲ្យខ្ញុំរស់ នាងទេវីក៏រស់ ឬមួយសម្លាប់ខ្ញុំ នាងទេវីក៏ស្លាប់ ។

មានន្ទប្រឹងនៅស្ងៀម ។ ក្នុងវិនាទីនេះ ចិត្តពីរប្រឡាស់គ្នាយកទង្គិចគ្នាយ៉ាងខ្លាំងក្នុងខ្លួនអ្នក ។

ចិត្តទីមួយ អាណិត ស្រណោះ ស្រឡាញ់នាងទេវីបណ្ដាលចិត្ត ដោយព្រាត់យូរហើយ ។ ដែលធ្លាប់ជាទីគោរពក្រៃពេក ។ ស្រីស្រស់ល្អបរិសុទ្ធរកគ្មានថែមទាំងមានចិត្តស្នេហាអ្នកពិត ។ ពេញសុផនស្រី ។ មើលចុះ ទឹកមុខនាងដែលពុំដែលបាត់សប្បាយ ចិញ្ចើមនាងដែលខ្មៅដូចគេគូរ ភ្នែកនាងដែលរលើបរលង់ទៅដោយទុក្ខ . . .

ឱ ! ស្រីអង្វរឲ្យទុកជីវិតនាង ។

ចិត្តមួយទៀត គឺចិត្តស្នេហាការងារ ស្នេហាជាតិ ។ ក្នុងការងារនេះនាងខត្តិយាណីជា ឧបសគ្គមួយដ៏ធំក្រៃលែង ។ បើលែងចោល

កញ្ញានេះអាចរំលាយអង្គការតស៊ូបាន !

ចិត្តទាំងពីរនេះស្ថិតនៅក្នុងរូបមានន្ទតែមួយ រួចច្បាំងគ្នាយ៉ាងគគ្រឹកគគ្រេង ។ ត្រូវតែចិត្តមួយឈ្នះលើចិត្តមួយ ។ ចិត្តទាំងពីរនេះពុំអាចនៅជាមួយគ្នាបានឡើយ ។ ឥឡូវ :

ឬទុកជីវិតនាងទេវី ទុះជាតិវេទនា ! !

ឬសម្លាប់នាងមណី នាងទេវីសម្លាញ់ស្លាប់ ! !

ចំណែកនាងទេវីវិញ ពីមុខរឿងនេះ តើស្រីគិតយ៉ាងណា ?

នាងនឹកថា ក្នុងមួយពេលនេះ បើមានន្ទសុខចិត្តឲ្យគេសម្លាប់នាង ប្រុសនេះហោចំជាប្រុសអាក្រក់មែនគ្មានចិត្តជាប្រុសឡើយ ។ នាងនឹកទៀតថា ការតស៊ូមិនមែនប្ដូរមនុស្សដូចប្ដូរអាវនោះទេតិមានល្បិចបន្ថែម។ រីឯជីវិតមនុស្សថ្លៃណាស់ ។ ស្រីជ្រួញចិញ្ចើម ស្រីឃើញថានាងស្លាប់ហើយ ស្រីឃើញថាមានន្ទប្ដីសម្លាញ់នាង សម្លាប់នាងនឹងដៃឯងហើយ ព្រោះទឹកមុខមានន្ទប្រឹង ។ បុរសប្រឹងគិត ប្រឹងទាល់តែដល់ចុងបំផុត បញ្ញាជាតិមានជ័យជម្នះលើសេចក្ដីស្នេហ៍ ។ មានន្ទខាំធ្មេញជាសញ្ញាប្រាប់ថាសម្លាប់នាងមណី សុខចិត្តឲ្យគេសម្លាប់ទេវីតាមក្រោយចុះ ។ ស្រីជាភរិយាខឹងធ្លាយឡើងណែនអស់ដើមទ្រូង ។

តែពេលដដែលនោះ ព្រួញពីររត់ពីមាត់បង្អួចខាងនោះ ធ្លុះចំត្រូវអ្នកចាប់នាងទេវីតឹប ៗ ។ ទាហានស្រែកអូយៗដួលច្រងាង ។ នាងទេវីស្ទុះរត់ទៅក្រៅ ។

នាងមាលាដែលមើល នឹងបាញ់ព្រួញអម្បាញ់មិញនោះជាមួយស្រីម្នាក់ទៀត ក៏រត់ទៅខ្ទប់ទ្វារមិនឲ្យនាងទេវីដែលយំហោយរត់រួចឡើយ ។

ទៅបន្តិចពីលើម្ខាងទៀត អារុណយឹតព្រួញត្រង់ចុងដង្ហើមព្រះនាងខត្តិយាណី ។ ព្រួញរត់ហោះមកបុកដើមទ្រូងនោះឮឌឹប ។ ស្រីស្ងួល ក្លួនស្រែកថា :

- អូយ ! អូយ !

មានន្ទក្រឡេកទៅលើឃើញវីរៈ មហាកាល និង មិត្តឯទៀតជាច្រើនមកដល់ដែរ កំពុងតដៃយ៉ាងរីករាយជាមួយខ្មាំង ។

ព្រះនាងមណីឈឺចុកកាយឱបខ្លួនក្នុងរង្វង់ដៃមានន្ទ ។ នាងនិយាយទៀតខ្សាវៗ ថា :

- បង ! បង ! ប្អូនសូមចងកម្ម . . . ចងពៀរវេរា . . . ជាមួយបងទៅជាតិមុខទៀត . . . សុំ ចង . . ចង . . ពៀរ . . . ពៀរ . .

ឮដូច្នោះ មានន្ទងក់ក្បាលនិយាយថា .

- បាន ! មិនអីទេ !

ធីតាក៏កម្រើកខ្លួនជាចុងក្រោយបំផុត ដើម្បីជូនសង្ខារស្រីទៅឲ្យមច្ចុរាជវិញ ។

នេះហើយអំពើទុច្ចរិត ដែលពីដើមមកធ្លាប់តែមានជ័យជម្នះ តែដល់ពេលមួយទុច្ចរិតតាមទាន់ ជនអ្នកជាតួឯកដែលសប្បាយនឹងលេងល្បែងនេះរមែងតែងចាញ់មិនខាន ។ អយុត្តិធម៌រស់បានតែដោយសារមនុស្សព្រាសចាកការតស៊ូ ខ្លាចញញើតទេ ។ ដរាបណាមនុស្សចេញពុះពារដោយម៉ឺងម៉ាត់ហើយ ដរាបនោះយុត្តិធម៌ និងសុចរិតធម៌ផុសឡើងមិនយូរឡើយ ។

ភ័ស្តុតាង ព្រះនាងមណីដែលទើបនឹងផ្តួលស្តូកស្តឹងស្លាប់ក្នុងថ្លុក

ឈាមសាក្រក់អម្បាញ់មិញនេះ ។

មានន្ទក្រោកឡើងជួយប្រកាប់ប្រចាក់នឹងគេ រួចក្រឡេកមើលខាងឆ្វេង ឃើញមហាកាលកំពុងតជាប់ដៃជាមួយកាឡា ។ ក្រឡេកមើលស្តាំឃើញនាងទេវីកំពុងបម្រះចេញពីដៃនាងមាលារកផ្លូវរត់ ។ និលឯកយឹតធ្នូបាញ់នាងទេវីផ្លូង ។ ព្រួញរត់ផាល់យ៉ាងលឿន ។ មានន្ទស្រែក :

- គេច ! អូន !

នាងមាលាកំពុងឱបប្រឹតប្រតោងនាងទេវី ។ ស្រីផាទាសីត្រូវនឹងព្រួញនិលឯកផតផ្ទួលខ្លោក ។ មានន្ទរត់ហោះទៅត្រកងបីស្រីស្នើម ដែលនិយាយតិចៗថា :

- ប្អូនសូមលា ! ស្តាយណាស់ . . . ការបដិវត្តយើងមិនទាន់ចប់ . . . ប្អូនមិនទាន់បានឃើញពន្លឺឯករាជ្យ . . . ពន្លឺសិទ្ធិ និងសេរីភាពផង ។

មានន្ទមុខស្រងូតឆ្លើយថា :

- កូនចៅយើងមុខជាបានឃើញមិនខាន ។

នាងមាលាញញឹមងក់ក្បាលបន្តិច រួចទន់ខ្លួនស្រិបមួយរំពេច ។ មានន្ទក្រោករត់ទៅចាប់ដៃ «មនុស្សឥតឈ្មោះ» ដែលបានជួយនាងទេវីកាលនៅបាត់ដំបងបញ្ចូលទៅគៀនមួយសួរយ៉ាងប្រញាប់ថា :

- លោកគ្រូ ! ម៉េចបានទ័ពរបស់រាជរដ្ឋាភិបាលទេ ?

- បាន ! កំពុងតតាំងគ្នាហ្នឹងហើយ

- អូស ! ផយោលោកគ្រូ ! ខ្ញុំស្មានតែទ័ពរបស់បងកាល ។

- ទេ ! ទេ ! ទ័ពនេះមកពីរាជធានីឧត្តុង្គមានជ័យណា៎

- អ្នក ណាទៅមក ?

- ខ្ញុំ

- ផះយោ ! លោកគ្រូ ! ប៉ុន្មាននាក់ ?

- ប្រាំពាន់

- ផះយោ ! លោកគ្រូ ! មានសំបុត្រទេ ?

- មាន

- ថាយ៉ាងម៉េចខ្លះ ?

- ចាំមើលជាក្រោយ ! ឥឡូវវាយទៅឲ្យអស់ដៃ ។

មានន្ទស្រែកបញ្ជាថា :

- វាយ ! អាតូន ! ចូលលុក !

មានន្ទបង្វិលខ្លួនទៅជិតមហាកាលសួរថា :

- បានមាសទេ ?

- បានស្រេច លោកគ្រូ !

- ផះយោ ! យើងអាចច្បាំងថ្លៃឆ្នាំទៀត ! ចូលអាតូន !

- ឥឡូវនៅឯណាមាសនោះ ?

- យកទៅដល់កន្លែងហើយ !

ការប្រឡូកប្រកាប់ប្រចាក់ក៏កើតមានយ៉ាងសាហាវ ។ គេឮសូរតែដាវដែលទង្គិចគ្នា និងសម្រែកក្មេងចាស់ដែលភ័យផ្អើល ។ មានន្ទវាយថយទៅជិត « លោកគ្រូឥតឈ្មោះ » ថា :

- លោកគ្រូ ! ធ្វើយ៉ាងម៉េចចាប់ស្តុកខ្ញុំឲ្យបានណា ?

- បាន !

វីរកាយា ដល់ឃើញពលរេហ៍ខាងខ្លួនមានចំនួនតិចជាង ក៏វាយថយខ្លួនចំទ្វារដាប់ រត់ទៅចាប់សេះមួយបំផាយរឹងទៅទិសខាងលិច ។ គឺចំលើផ្លូវទៅក្រុង « អយុធ្យា » ។ មានន្ទរត់ស្ទាត់ដោយបានផ្ទោះទៅតាមបន្តិច ។ កាយាទើបបានចម្ងាយប្រមាណដប់ម៉ែត្រ ។ យ៉ិតគ្នាបាញ់មុំរឹងព្រួញហោះផាល់ទៅត្រូវខ្នងកាយាតែបតែសេះផាយយ៉ាងលឿនទៅទៀត ។ កាយាដួលខ្លួនឱបខ្នងសេះ រួចមិនយូរប៉ុន្មានបុរសក៏ធ្លាក់ជាវែងពីខ្នងអាជានេយ្យ ។

ពលរេហ៍ កាលបើអស់មេបញ្ជា ក៏រត់ខ្ចាត់ខ្ចាយ ។ តែពួកកងពលខាងយើងអត់ឲ្យរត់រួចឡើយ ទាំងគ្នាដេញតាមវាយប្រហារយ៉ាងឃោរឃៅ ។ ក្រឡេកមើលទៅខាងត្បូងមានន្ទឃើញសេះសមួយដោលទៅឆ្ងាយ ។ លើអស្សពាហ៍ បុរសស្គាល់ជាក់ជានាងទេវី ភរិយាសម្លាញ់តែមួយដែលព្រោកផ្ទាអាក់អន់ចិត្តរត់ចោលអ្នកវិញ ។ មាណពចាប់បានសេះមួយបំផាយតាមឥតបង្អង់ឡើយ ។

លឿនប្រិច ។ សេះមានន្ទកាន់តែជិតសេះស្រីវលក្ខណ៍ឡើង ជិតឡើង ។ លុះដល់កណ្តាលវាលជិតដើមពោធិ ដែលកាលប្រាំឆ្នាំមុនអ្នកបានប្រកាប់គ្នាជាមួយកាយាបុរសលោភល្មោភទៅចាប់នាងទេវី ដែលដួលទៅទីនេះ ។ នៅពីក្រោយស្វាមីស្រីចប្រុះយ៉ាងអស់ទំហឹង តែមានន្ទសង្កត់ជាប់ ។ មួយស្របក់ធំ កម្លាំងទេវីក៏អស់ហើយ ញើសចេញពេញ



... ឃ្លាមក សេចក្ដីរលឹកប្ដី សេចក្ដីស្នេហា
សេចក្ដីគោរពបើកទ្វារក្នុងដួងចិត្តពិគាបន្តិចម្ដង ៗ

ទាំងមុខ ។ ស្រីធ្មេចភ្នែក ដើម្បីកុំឲ្យឃើញមុខប្រុសដ៏កំណាចដែលនាងស្រឡាញ់យូរណាស់មកហើយ។ ដែលជាហេតុនៃកងទុក្ខរបស់នាងនេះ។ មានខ្លួនបវិតស្រី ដែលគេចមុខចុះឡើងលើធរណី ដើម្បីកុំឲ្យស្វាមីដែលទើបចង់សម្លាប់ថ្មីៗ នេះដាក់ច្រមុះផិតនាងបាន ។

មានខ្លួនប្ដេជ្ញាថា ដរាបណាប្អូនទេវសម្លាញ់ចិត្តមិនទាន់អស់ទឹងទេ ដរាបនោះអ្នកមិនលែងសង្កត់នាងឡើយ ។

អ្នកណាឈ្នះ ? អ្នកណាចាញ់ ?

ជនទាំងពីរឥតនិយាយអ្វីឡើយ រង់ចាំតែកាយវិការប៉ុណ្ណោះឯងដែលសំដែងទឹកចិត្តរៀង ៗ ខ្លួន ។ នាងទើបទន់អស់ដៃជើង ប្រឹងប្រទះទៅទៀតលែងរួចឡើយ គឺនៅតែក្បាលដែលរេចុះ រេឡើងលើស្មាខ្លី ។ ឃ្លាមក សេចក្ដីរលឹកប្ដី សេចក្ដីស្នេហា សេចក្ដីគោរពបើកទ្វារក្នុងដួងចិត្តពិគាបន្តិចម្ដង ៗ ។

ទ្វារកាយគុណនេះធ្វើឲ្យទឹកភ្នែកស្រីហូរជាថ្មី នេត្រាកំសត់នេះក៏មើលចំនេត្រាស្វាមី ។ នាងឃើញរូបនាងក្នុងកែវភ្នែកប្ដីកំសត់នេះ ដែលអង្វរសូមទោសនាងហើយ ។ សេចក្ដីអាណិត ចូលមកបន្ថែមលើកម្លាំងស្នេហាទៀត ដៃស្ដើងក៏រួម ។ ឱបស្មាសង្សារកាន់តែតឹងឡើង ៗ ។

មានខ្លួនរឹបផាត់ត្រចៀកនាង សួរថា :

- កូនយើងនៅឯណា ?
- នៅភូមិថ្មី ផ្ទះយាយម៉ាវ៉ា
- អូនឯងមកនៅផ្ទះដែលមណីស្លាប់ ប៉ុន្មានថ្ងៃហើយ ?



[illegible] …

- ពីរថ្ងៃ

- អូនមកជាមួយអ្នកណា ?

- ជាមួយទាហាន

- គេចាប់ឬ ?

- ចាះ ! ពីមុនខ្ញុំនៅបាត់ដំបង គាត់ម្នាក់ជួយខ្ញុំ យកខ្ញុំមកនៅភូ
ថ្មី ។ ពីរថ្ងៃមុននេះ មានទាហានទៅតាមចាប់ខ្ញុំមក ។

មានទូឱបរឹតថើបស្រីយ៉ាងខ្លាំង ដែលនិយាយទៅទៀតលែងរួច ។

នៅឯសមរភូមិ ស្នូរគ្រាប់បញ្ចប់សង្គ្រាមក៏លាន់ឮឡើង ។

មានទូលើកស្រីឡើងក្រោកឈរ ។ អ្នកបំបមតិតាផាត់លើខ្នងសេះ
រួចនាំស្រីបញ្ជិះទៅឯកងទ័ពឯភូមិវិញ ។

មហាកាល អារុណ លោកគ្រូគតឈ្មោះ វីរៈ នាយកងបញ្ជាស្ស
ទាហានឈរជាជួរដើម្បីធ្វើការគិច្ចចំពោះមេទ័ពយើង ។

មហាជនរាប់ពាន់នាក់ឈរត្រៀបត្រាស្រែក "*ជយោ ! មានទូ!
ជយោ ! មានទូ ! ជយោ ! ឯករាជ្យ ! ជយោ ! ឯករាជ្យ !*"

មានទូ និង នាងទេវី លើកដៃគ្រវីជាសញ្ញាគប់សំណេះគុណវិញ
ដោយងាកមើលមុខគ្នាទៅវិញទៅមកយ៉ាងញឹកញាយបំផុត -៕

—ចប់